ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ភ្នំពេញ, ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មានរួម
# ស្តីពីពិធីចុះហត្ថលេខា
# លើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង
# រវាងរាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

នៅព្រឹកថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង លោក Yuichi SUGANO ប្រធានតំណាង JICA ប្រចាំនៅកម្ពុជា នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង សម្រាប់អនុវត្តគម្រោងអភិវឌ្ឍប្រព័ន្ធបង្ហូរទឹកកខ្វក់ក្នុងរាជធានីភ្នំពេញ (*The Project for Sewerage System Development in Phnom Penh*) ដែលមានទឹកប្រាក់ចំនួន **២ ៧៧៧** លានយ៉េន (ប្រមាណជា **២៧** លានដុល្លារអាមេរិក)។

គម្រោងអភិវឌ្ឍប្រព័ន្ធបង្ហូរទឹកកខ្វក់ក្នុងរាជធានីភ្នំពេញនេះ មានទិសដៅចម្រោះទឹកកខ្វក់មុនពេលបង្ហូរចូលទន្លេ តាមរយៈការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់មួយកន្លែងនៅបឹងជើងឯក ក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ និងបំពង់បង្ហូរទឹកកខ្វក់ដែលមានប្រវែង ២ ០០០ ម៉ែត្រ មុខកាត់ ៥០០ ម.ម ភ្ជាប់ពីស្ថានីយ៍បូមទឹកកខ្វក់បឹងត្របែក។ រោងចក្រប្រព្រឹត្តកម្មនេះ មានសមត្ថភាពចម្រោះទឹកកខ្វក់បាន ៥ ០០០ ម៉ែត្រគូបក្នុងមួយថ្ងៃ។ ការសាងសង់នឹងត្រូវចាប់ផ្តើមនៅចុងឆ្នាំ២០២០ ដែលមានរយៈពេលប្រមាណ ៣២ខែ។ បន្ថែមពីលើការសាងសង់ គម្រោងក៏នឹងផ្តល់ជំនួយបច្ចេកទេសសម្រាប់ពង្រឹងសមត្ថភាពមន្ត្រីលើប្រតិបត្តិការនិងថែទាំរោងចក្រ ព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុផងដែរ។ វាគឺជា គម្រោងទី១ក្នុងរាជធានីភ្នំពេញ ដែលនឹងបំពេញបន្ថែមឲ្យគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយលូក្នុងរាជធានីភ្នំពេញ ជំហានទី១ ទី២ ទី៣ និងទី៤ ដែលត្រូវបាន សាងសង់ដោយហិរញ្ញប្បទានឥតសំណងរបស់ប្រទេសជប៉ុនផងដែរ។ គម្រោងនេះ នឹងចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់សាលារាជធានីភ្នំពេញ ក៏ដូចជា

រាជរដ្ឋាភិបាលកម្ពុជា ដោយបានឆ្លើយតបយ៉ាងជាក់ច្បាស់ទៅនឹងសេចក្តីត្រូវការជាអាទិភាពក្នុងការ អភិវឌ្ឍប្រព័ន្ធចម្រោះទឹកកខ្វក់ ដែលនាំមកនូវការការពារ និងលើកម្ពស់គុណភាពទឹក និង អនាម័យបរិស្ថាន ស្របទៅនឹង**មុំទី១នៃចតុកោណទី៤ ដូចមានចែងក្នុងឯកសារយុទ្ធសាស្ត្រ ចតុកោណ ដំណាក់ កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។**

កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងដែលនឹងត្រូវចុះហត្ថលេខានេះ គឺជាឯកសារគតិយុត្តិមួយទៀត បន្ទាប់ពីលិខិតប្តូរសារដែលទើបត្រូវបានចុះហត្ថលេខា កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០១៩ កន្លងទៅ រវាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា និងស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា ដែលអាចនាំឲ្យឈានទៅដល់ការអនុវត្តនីតិវិធីបន្តបន្ទាប់ទៀតសម្រាប់ការអនុវត្តគម្រោងជាក់ស្តែង។

សូមរំលឹកថា រាប់ទាំងកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងនេះ ក្នុងឆ្នាំ២០១៩ រដ្ឋាភិបាលជប៉ុន តាមរយៈ JICA បានចុះហត្ថលេខា លើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចំនួន ៩គម្រោង ដែលមានទឹកប្រាក់សរុបចំនួន **៨ ០៥៥ លានយ៉េន ត្រូវជាប្រមាណ ៧៧ លានដុល្លារអាមេរិក** ក្នុងនោះរួមមានហិរញ្ញប្បទានឥតសំណងប្រមាណជាង ៤៣ លានដុល្លារអាមេរិក និងឥណទានសម្បទានប្រមាណជិត ៣៤ លានដុល្លាអាមេរិក។

<u>សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់៖</u>


- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ លោក រៀម ឧត្តម តាមរយៈអ៊ីម៉ែល utdom.mef@gmail.com ឬទូរស័ព្ទលេខ ០១៧ ២៧២ ៧៧៦
- ការិយាល័យ JICA ប្រចាំកម្ពុជា៖ កញ្ញា ម៉ា សុភាវីន មន្ត្រីកម្មវិធី តាមរយៈអ៊ីម៉ែល Ma-Sopheavin@jica.go.jp ឬទូរស័ព្ទលេខ ០៩៥ ៦៦៦ ១០៦។


******************